ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
លេខ: ០០៧/១១ អជដ

# សេចក្តីសម្រេច

## ស្តីពី

## ការអនុវត្តជំហានទី ២ នៃលិខិតលេខ ១៤២១ សជណ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## ឧបនាយករដ្ឋមន្ត្រី
## ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
## និងជាប្រធានគណៈកម្មការអធិការកិច្ចលើការគ្រប់គ្រង និងអភិវឌ្ឍន៍ឡូត៍នេសាទ ជុំវិញបឹងទន្លេសាប

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹកនៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីជលផល
- បានឃើញសេចក្តីសម្រេចលេខ ៣៩ សសរ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតគណៈកម្មការអធិការកិច្ច លើការគ្រប់គ្រង និងអភិវឌ្ឍន៍ឡូត៍នេសាទជុំវិញបឹងទន្លេសាប
- បានឃើញលិខិតលេខ ១០០១ សជណ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីឡូត៍នេសាទទាំង ៣៥ ឡូត៍ នៅខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ជុំវិញបឹងទន្លេសាប

-បានឃើញសារាចរលេខ ០៩ សរណន ស្តីពីការគ្រប់គ្រងឡូត៍នេសាទដែលបានដកហូតចំនួន ៣៥ ឡូត៍ ជុំវិញបឹងទន្លេសាប នៅខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ជុំវិញបឹងទន្លេសាប

-បានឃើញលិខិតលេខ ១៩២១ សជណ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីបទល្មើសនេសាទ នៅតំបន់បឹងទន្លេសាប

-ដោយពិនិត្យឃើញថា បណ្តាខេត្តពាក់ព័ន្ធនឹងឡូត៍នេសាទដែលបានដកហូតនៅជុំវិញបឹងទន្លេសាប កំពុងមមាញឹកក្នុងការងារបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ-សង្កាត់ នាពេលខាងមុខ

-ដោយពិនិត្យឃើញថាស្ថានភាពបទល្មើសជលផលចេះតែបង្កកើនឡើងឥតឈប់ឈរ នៅតាមបណ្តាខេត្តជុំវិញបឹងទន្លេសាប ពិសេសនៅក្នុងឡូត៍នេសាទទាំង ៣៥ ដែលបានដកហូត

-ដើម្បីសង្គ្រោះធនធានមច្ឆជាតិនៅក្នុងបឹងទន្លេសាប និងការប្រើប្រាស់ធនធាននេះប្រកបដោយនិរន្តរភាព

## សម្រេច

**ប្រការ ១ :** ចាប់ផ្តើមអនុវត្តជំហ៊ានទី ២ នៃលិខិតលេខ ១៩២១ សជណ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ប្រគល់ភារកិច្ចជូនអាជ្ញាធរទន្លេសាបចុះបង្ក្រាបបទល្មើសនេសាទ នៅតាមបណ្តាឡូត៍នេសាទដែលបានដកហូតនៅជុំវិញបឹងទន្លេសាប។

**ប្រការ ២ :** អនុប្រធាន និងសមាជិកគណៈកម្មការអធិការកិច្ច លើការគ្រប់គ្រង និងអភិវឌ្ឍន៍ឡូត៍នេសាទ ជុំវិញបឹងទន្លេសាប ត្រូវបង្កលក្ខណៈសម្បត្តិជូនអាជ្ញាធរទន្លេសាប ដើម្បីអនុវត្តភារកិច្ចខាងលើប្រកបដោយលទ្ធផលល្អប្រសើរ។

**ប្រការ ៣ :** អនុប្រធាន និងសមាជិកគណៈកម្មការអធិការកិច្ច លើការគ្រប់គ្រង និងអភិវឌ្ឍន៍ឡូត៍នេសាទ ជុំវិញបឹងទន្លេសាប និងអាជ្ញាធរទន្លេសាប ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១១

**ឧបនាយករដ្ឋមន្ត្រី**

ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងជាប្រធានគណៈកម្មការ អធិការកិច្ចលើការគ្រប់គ្រង និងអភិវឌ្ឍន៍ឡូត៍នេសាទ ជុំវិញបឹងទន្លេសាប

**ប៊ិន ឈិន**

**កន្លែងទទួល:**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ក្រសួង-ស្ថាប័នពាក់ព័ន្ធ
-សាលាខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប កំពង់ធំ កំពង់ចាម កណ្តាល និងខេត្ត បន្ទាយមានជ័យ
-ដូចប្រការ ៣
-ឯកសារកាលប្បវត្តិ